ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
អគ្គលេខាធិការដ្ឋាន
លេខ : ០០៤/១២.អ.ជ.ប.គ.ញ
១២

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១២

# របាយការណ៍

## ស្តីពី

## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែ ធ្នូ ឆ្នាំ ២០១១
## និង ទិសដៅការងារ ខែ មករា ឆ្នាំ ២០១២

(គិតចាប់ពីថ្ងៃទី ២៦/១១/២០១១ ដល់ ថ្ងៃទី ២៥/១២/២០១១)

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់អនុវត្តតាមយុទ្ធសាស្ត្រពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ដើម្បីចូលរួមចំណែកអនុវត្ត "គោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព" របស់រាជរដ្ឋាភិបាល សំដៅរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សង្គម ស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៤នៃរដ្ឋសភា ។ ជាក់ស្តែង លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលបានអនុវត្តនៅក្នុង ខែ ធ្នូ ឆ្នាំ ២០១១ នេះ មានដូចខាងក្រោម :

## I. សភាពការណ៍គ្រឿងញៀននៅកម្ពុជា

ខែធ្នូឆ្នាំ២០១១នេះ ក្រុមឈ្មួញគ្រឿងញៀននៃប្រទេសជិតខាងនៅតែបន្តនាំគ្រឿងញៀនសំយោគប្រភេទ **មេតំហ្វេតាមីនគ្រាប់** (អក្សរ WY) និង **មេតំហ្វេតាមីនទឹកកក** (ICE) ចូលមកក្នុងប្រទេសតាមច្រកនៃបណ្តាខេត្តព្រំដែនភាគឦសាន ដើម្បីនាំបន្តទៅកាន់តំបន់ព្រំដែនភាគពាយ័ព្យ, មួយចំនួនធ្វើការចរាចរចែកចាយនៅតាមបណ្តាខេត្តនានានៅក្នុងប្រទេស និងមួយចំនួននាំទៅតំបន់ព្រំដែនភាគខាងកើតប្រទេស ជាក់ស្តែងយើងបានរកឃើញជនសង្ស័យជាឈ្មួញនៃប្រទេសជិតខាង ចំនួន ៦ នាក់ ជាជនជាតិ ថៃ និង វៀតណាម ។ ដោយឡែក ក្រុមស៊ីឈ្នួលនាំគ្រឿងញៀនរបស់ក្រុមឈ្មួញគ្រឿងញៀនអន្តរជាតិ ក៏នៅតែបន្តធ្វើសកម្មភាពជួញដូរគ្រឿងញៀននៅក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ជាក់ស្តែងសមត្ថកិច្ចបានរកឃើញនិងឃាត់ខ្លួន ចំនួន ៤ នាក់ ជាជនជាតិ សេរ៉ាឡេអូន នីហ្សេរីយ៉ា ម៉ាឡេស៊ី និង បារាំង ។ ជាមួយនេះ នគរបាលខេត្តកំពង់ឆ្នាំងក៏បានរកឃើញករណីដឹកជញ្ជូនប្រេងម្រះព្រៅភ្នំ ១ ករណីផងដែរនៅក្នុងខែធ្នូនេះ ។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់លើការដឹកនាំ និង ណែនាំឱ្យអនុវត្តយុទ្ធសាស្ត្រពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន (ខ្លឹមសារដឹកនាំនិងណែនាំមាននៅក្នុងឧបសម្ព័ន្ធ) ។ ផ្តើមចេញពីគោលការណ៍ដឹកនាំនិងណែនាំខាងលើ អាជ្ញាធរជាតិបានខិតខំអនុវត្តទទួលលទ្ធផលដូចខាងក្រោម :

### *១. ការកាត់បន្ថយតម្រូវការគ្រឿងញៀន*

#### *១.១. សកម្មភាពអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ រួមមាន :*

- **អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣** បានបន្តសហការសម្របសម្រួលជាមួយក្រសួងព័ត៌មាន តាមរយៈការជំរុញឱ្យក្រុមសិល្បករ ពិធីករ តន្ត្រីករ តាមបណ្តាស្ថានីយ៍វិទ្យុ និង ទូរទស្សន៍ រដ្ឋ និង ឯកជន បង្កើនសកម្មភាពផ្សព្វផ្សាយអប់រំអំពីគ្រោះថ្នាក់នៃគ្រឿងញៀន ។
- **អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣** បានសហការជាមួយក្រសួងព័ត៌មាន ចូលរួមក្នុងមហោស្រពចម្រៀងថ្នាក់ជាតិ ឆ្នាំ២០១១ នៅស្ថានីយទូរទស្សន៍ជាតិកម្ពុជា កាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១១ ដោយមានការឧបត្ថម្ភជាប្រាក់រង្វាន់លើកទឹកចិត្តដល់ក្រុមតន្ត្រីករ ពិធីករ ដែលបានច្រៀងបទចម្រៀង និងផ្សព្វផ្សាយពីគ្រោះថ្នាក់នៃគ្រឿងញៀន ។
- **ក្រសួងមហាផ្ទៃ** តាមរយៈកម្មវិធីសន្តិសុខមាតុភូមិ បានបន្តការផ្សព្វផ្សាយស្ព័តអប់រំបង្ការការប្រើប្រាស់គ្រឿងញៀនតាមកម្មវិធីប្រចាំថ្ងៃរបស់ស្ថានីយទូរទស្សន៍នានា ។
- **ក្រសួងកិច្ចការនារី** បានបន្តជំរុញការផ្សព្វផ្សាយអប់រំ ស្តីពីអំពើហឹង្សាទាក់ទងនឹងយេនឌ័រ និងសារសំខាន់៧ពាក់ពន្ធ័នឹងការបង្ការទប់ស្កាត់គ្រឿងញៀន តាមវិទ្យុនិងទូរទស្សន៍ ។
- **ក្រសួងធម្មការនិងសាសនា** បានបន្តការអនុវត្តកម្មវិធីសន្ទនាព្រះធម៌ តាមរយៈនាទីព្រះពុទ្ធសាសនាផ្សារភ្ជាប់នឹងសង្គម ដើម្បីលើកកម្ពស់សីលធម៌រស់នៅល្អក្នុងសង្គម ចៀសផុតពីការប្រើប្រាស់គ្រឿងញៀន និងអំពើហឹង្សា ។
- **ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ** បានបន្តណែនាំដល់ផលិតកម្មភាពយន្ត-វីដេអូ និងក្រុមហ៊ុន នាំចូល-នាំចេញ ខ្សែភាពយន្ត-វីដេអូ ឱ្យដាក់ **សារ** អប់រំពីគ្រឿងញៀននៅលើផលិតផលរបស់ខ្លួន ។
- **ក្រសួងទេសចរណ៍** បានបន្តចាក់ផ្សាយ Spot "កម្ពុជាព្រះរាជាណាចក្រអច្ឆរិយៈ" ជាភាសាខ្មែរ-ភាសាបរទេស តាមទូរទស្សន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងនៅតាមទូរទស្សន៍បរទេស រួមទាំងចលនាប្រឡងប្រណាំង "ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាកម្មល្អ" ដែលមានបង្កប់សារអប់រំពីបញ្ហាគ្រឿងញៀន ។

**ដោយឡែក** គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តតាកែវ បានចូលរួមផ្តល់កិច្ចសម្ភាសន៍តាមកម្មវិធីប្រចាំខែដែលផ្តល់ដោយស្ថានីយទូរទស្សន៍ CTN ស្តីពីសភាពការណ៍ និងលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនរបស់ខេត្ត ។

#### *១.២. សកម្មភាពផ្សព្វផ្សាយអប់រំតាមសហគមន៍ជាតិ :*

- **អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣** បាន
    - សម្របសម្រួលជាមួយក្រសួងអប់រំយុវជន និងកីឡា និងអាជ្ញាធរដែនដី ដើម្បីឱ្យសមាគមយុវជនខ្មែរ បានបន្តការបើកវគ្គបណ្តុះបណ្តាល ការចងក្រងក្លឹបយុវជន សកម្មភាពអប់រំរបស់ក្លឹបយុវជន និងសិក្ខាសាលាស្តីពីការ

អប់រំបង្ការគ្រឿងញៀន នៅតាមវិទ្យាល័យ ឃុំ-សង្កាត់ ក្នុងរាជធានីភ្នំពេញ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និង ខេត្តសៀមរាប ។

- ចូលរួមក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេស ស្តីពីការអប់រំបង្ការជំងឺអេដស៍ ក្នុងវិស័យអប់រំដែលមានពាក់ពន្ធ័នឹងការប្រើបំពានគ្រឿងញៀន កាលពីថ្ងៃទី០២ខែធ្នូឆ្នាំ២០១១(រៀបចំដោយក្រសួងអប់រំ យុវជននិងកីឡា) ។
- បានចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការអន្តរនាយកដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ និងគ្រឿងញៀន របស់ក្រសួងអប់រំយុវជន និងកីឡា កាលពីថ្ងៃទី ២៧/១២/២០១១ ក្រោមអធិបតីភាពឯកឧត្តម **អ៊ឹម សិទ្ធី** រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា ដែលមានសមាសភាពពាក់ពន្ធ័ចូលរួម សរុបចំនួន ១០០ នាក់ ។ ឯកឧត្តមរដ្ឋមន្ត្រីបានណែនាំឱ្យបន្តរៀបចំបង្កើតផែនការសកម្មភាព និងជំរុញការអនុវត្តសំដៅធ្វើយ៉ាងណាឈានទៅសម្រេចនូវយុទ្ធ-សាស្ត្រ ៣-0 ក្នុងការងារប្រយុទ្ធប្រឆាំងជំងឺអេដស៍ និងឈានទៅកសាងបាននូវសាលារៀនពណ៌បៃតង ។ កិច្ចប្រជុំបានធ្វើបទបង្ហាញពាក់ពន្ធ័នឹងប្រធានបទ "គ្រឿងញៀន និងការអប់រំ" ដែលមាន ៥ ចំណុចគឺ ប្រវត្តិនៃគ្រឿងញៀន, អត្តសញ្ញាណនៃគ្រឿងញៀន, និន្នាការថ្មីនៃគ្រឿងញៀននៅក្នុងតំបន់ដែលត្រូវយកចិត្តទុកដាក់, វិធានការឆ្លើយតបរបស់រាជរដ្ឋាភិបាល អ.ជ.ប.គ.ញ ពិសេសពាក់ពន្ធ័នឹងយន្តការ និងសកម្មភាពផ្សព្វផ្សាយអប់រំធ្វើឱ្យមានការយល់ដឹងជាសាធារណៈពីគ្រឿងញៀន, សេចក្តីព្រាងឯកសារសម្រាប់កសាងសាលារៀនពណ៌បៃតង និងវិធានការការពារខ្លួនពីគ្រោះថ្នាក់គ្រឿងញៀន ។

- **ក្រសួងទេសចរណ៍**
  - បានបន្តជំរុញឱ្យមន្ទីរទេសចរណ៍រាជធានី-ខេត្ត អនុវត្តតាមស្មារតីអនុក្រឹត្យស្តីពីមគ្គុទ្ទេសក៏ទេសចរណ៍ ដែលមានបង្កប់សារអប់រំពីបញ្ហាគ្រឿងញៀន ។
  - បានជំរុញមន្ទីរទេសចរណ៍រាជធានី-ខេត្ត ឱ្យបិទផ្សាយនូវបណ្ណ័ផ្សព្វផ្សាយអំពីគ្រឿងញៀន អេដស៍ ការជួញដូរមនុស្ស និងការជួញដូរអាវុធជាតិផ្ទុះ នៅតាមគោលដៅសេវាកម្មទេសចរណ៍ (ផ្ទះសំណាក់, សណ្ឋាគារ កន្លែងកម្សាន្ត នានា) ។
  - បានជំរុញមន្ទីរទេសចរណ៍រាជធានី-ខេត្ត សហការជាមួយសមាគមសណ្ឋាគារ សេវាកម្មស្នាក់នៅទេសចរណ៍ សមាគមដឹកជញ្ជូនទេសចរណ៍ សេវាកម្មក្លឹបកម្សាន្តទេសចរណ៍ ម៉ាស្សា ខារ៉ាអូខេ ដើម្បីចុះផ្សព្វផ្សាយពីគ្រោះថ្នាក់នៃគ្រឿងញៀន និងតាមរយៈការបញ្ជ្រាបយេនឌ័រ នៅខេត្តតំបន់ ឆ្នេរសមុទ្រ រួមមាន ខេត្តព្រះសីហនុ ខេត្តកោះកុង ខេត្តកំពត ខេត្តកែប ដល់ប្រតិបត្តិករទេសចរណ៍ និង បុគ្គលិកបម្រើសេវាកម្មទេសចរណ៍ ។
- **ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងពាណិជ្ជកម្ម** បានបន្តជំរុញវិស័យឯកជនអនុវត្តការបិទសារអប់រំពីផលប៉ះពាល់នៃគ្រឿងញៀន នៅលើផលិតផលភេសជ្ជៈ ម្ហូបអាហារ និងផលិតផលផ្សេងៗរបស់ក្រុមហ៊ុនខ្លួន ។
- **ក្រសួងសាធារណការនិងដឹកជញ្ជូន** បានបន្តសហការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក(មាត្រា ៧៥ ពាក់ពន្ធ័នឹងការធ្វើតេស្តជាតិអាកុលនិងគ្រឿង ញៀន) និងបន្តអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងការប្រកបអាជីវកម្មផ្លូវថ្នល់ (មាត្រា ១២ ពាក់ពន្ធ័នឹងការហាម ឃាត់ការដឹកជញ្ជូនទំនិញមានគ្រោះថ្នាក់ ទំនិញមានក្លិនអាក្រក់ ទំនិញដែលរដ្ឋហាមឃាត់ ដូចជា គ្រឿងញៀន ជាដើម) ។

សកម្មភាពផ្សព្វផ្សាយអប់រំដោយផ្ទាល់នៅតាមសហគមន៍របស់ក្រសួង-ស្ថាប័ន ដែលមានការពាក់ពន្ធ័ រួមទាំងសកម្មភាពផ្សព្វផ្សាយអប់រំជាប្រចាំរបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តចំនួន ៦ (ដូចមាននៅក្នុងតារាងឧបសម្ព័ន្ធ) មានអ្នកចូលរួមសរុបចំនួន ***៣.២៨៨*** នាក់ ។

## ***២. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន***

ខែធ្នូឆ្នាំ២០១១នេះ មន្ត្រីអនុវត្តច្បាប់គ្រប់សមាសភាព និងគ្រប់លំដាប់ថ្នាក់ បានបន្តអនុវត្តយុទ្ធសាស្ត្រក្នុងការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន ទទួលបានលទ្ធផលដូចខាងក្រោម :

### ***២.១. ការបង្ក្រាបបទល្មើសគ្រឿងញៀន***

**-បទល្មើសគ្រឿងញៀន** បង្ក្រាបបាន **៤៥** ករណី / លើ ៣១ ករណី ប្រៀបធៀប ខែវិច្ឆិកា ឆ្នាំ២០១១ កើនឡើង ៤៥,១៦ % ។

**-ជនសង្ស័យ** ឃាត់ខ្លួនចំនួន **១០៦** នាក់/លើ ៧៨ នាក់ ប្រៀបធៀបខែវិច្ឆិកាឆ្នាំ២០១១ កើនឡើង ៣៥,៨៩ % ។ ក្នុងនោះ ចាប់តាមដីកាមាន ៣ ដីកា (ជនជាតិខ្មែរ ៣ នាក់ ប្រុស) ឃាត់ខ្លួនក្នុងបទល្មើសជាក់ស្តែង (១០៣ នាក់ / ស្រី១៨នាក់) រួមមាន ជនជាតិ ខ្មែរ ៩៦ នាក់ (ស្រី១៦នាក់), វៀតណាម ៥ នាក់ (ស្រី២នាក់), ថៃ ១ នាក់ (ប្រុស), សេរ៉ាឡេអូន ១នាក់ (ប្រុស), នីហ្សេរីយ៉ា ១នាក់(ប្រុស) ម៉ាឡេស៊ី ១នាក់ (ប្រុស), បារាំង ១នាក់ (ប្រុស) ។ ជនសង្ស័យទាំងអស់ ត្រូវបានសមត្ថកិច្ចកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូង រាជធានី-ខេត្ត ។

**-វត្ថុតាងគ្រឿងញៀនសំខាន់ៗ** រួមមាន :

មេតំហ្វេតាមីនគ្រាប់(អក្សរ WY) ៣.0៧៣ គ្រាប់, មេតំហ្វេតាមីនទឹកកក (Ice) ១៤៨,៩២ ក្រាម, ហេរ៉ូអ៊ីន ១,២ ក្រាម, កញ្ឆាក្រៀម ១២០ ក្រាម, អ៊ិចស្តាស៊ី ១.២៥0 គ្រាប់, ប្រេងម្រះព្រៅភ្នំ ១.១00 លីត្រ ។

**-ទ្រព្យសម្បត្តិពាក់ពន្ធ័នឹងបទល្មើសគ្រឿងញៀនសំខាន់ៗ** រួមមាន :

ប្រាក់ ៥៨៤.៥00 រៀល, ប្រាក់ដុល្លារ ១៦៩ ដុល្លារ ស.រ.អា, ប្រាក់បាត ២០០ បាត, រថយន្ត ១ គ្រឿង, ម៉ូតូ ១៥ គ្រឿង រួមទាំងវត្ថុតាងផ្សេងទៀតដូចមានរាយនៅក្នុងឧបសម្ព័ន្ធ ។

### ***២.២. ការធ្វើកោសល្យវិច័យលើសំណាកវត្ថុតាង***

**មន្ទីរពិសោធន៍គ្រឿងញៀន** របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានធ្វើកោសល្យវិច័យលើសំណាកវត្ថុតាងក្នុងខែធ្នូឆ្នាំ២០១១ បានចំនួន ៥៦ ករណី = ៦៣ សំណាក ក្នុងនោះ សំណាក **អវិជ្ជមានសារធាតុញៀន** ៣ សំណាក = ៤,៧៥ % និងសំណាក **វិជ្ជមានសារធាតុញៀន** មាន ៦0 សំណាក = ៩៥,២៥ % គឺ ៖

-មេតំហ្វេតាមីនទឹកកក (Ice) ៣៥ សំណាក = ៥៥,៥៦ % -មេតំហ្វេតាមីនគ្រាប់ ២៤ សំណាក = ៣៨,១0 %

-កេតាមីន ១ សំណាក = ១,៥៩ %

### ***២.៣. ការត្រួតពិនិត្យ និងការគ្រប់គ្រងសារធាតុគីមីផ្សំ***

- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានសហការជាមួយ ក្រសួងសុខាភិបាល ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីប្រមូលទិន្នន័យសារធាតុគីមីផ្សំ ដែលមានច្បាប់អនុញ្ញាតឱ្យនាំចូល

នៅក្នុងខែ ធ្នូ ឆ្នាំ២០១១ នេះ សរុបមានចំនួន **២.៨៩១.៩០៥** គ.ក្រ, **៥៦៨** លីត្រ, **២០** អំពូល និង **១១២** បារ៉ែល ( មានរាយមុខសារធាតុគីមីក្នុងតារាងឧបសម្ព័ន្ធ) ។

- បានស្រង់ទិន្នន័យផលិតផលឱសថដែលមានសារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ រួមមាន Stilnox ចំនួន **១** គ.ក្រ និង **៧១៤** ក្រាម, Alprazolam ចំនួន **២០០** ក្រាម, Lorazepam ចំនួន **៣០០** ក្រាម, Bromazepam ចំនួន **៣** គ.ក្រ និង **៦១៨** ក្រាម, Nordazepam ចំនួន **៦៧៥** ក្រាម ។
- បានធ្វើការបូកសរុបរបាយការណ៍ស្តីពីលទ្ធផលនៃការចុះសិក្សាស្រាវជ្រាវ ប្រមូលព័ត៌មានពាក់ពន្ធ័នឹងការចរាចរ និងការប្រើប្រាស់សារធាតុគីមីផ្សំ នៅខេត្តកណ្តាល ស្វាយរៀង កំពង់ចាម តាកែវ និង ខេត្តកំពត ។

## ៣. ការព្យាបាល / ស្តារនីតិសម្បទា និងការកាត់បន្ថយគ្រោះថ្នាក់

### ៣.១. ការងារព្យាបាល / ស្តារនីតិសម្បទា

**អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ**

- បានចូលរួមក្នុងកិច្ចប្រជុំ Core Group លើកទី១ ដើម្បីបន្តពិភាក្សាស្តីពីការបន្ត ការបង្ការ ថែទាំ ព្យាបាល និងស្តារនីតិសម្បទាក្នុងចំណោមអ្នកប្រើប្រាស់គ្រឿងញៀន (រៀបចំដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ១៦/១២/២០១១) ។
- បានផ្ទេរការផ្តល់របបឧបត្ថម្ភគោលនយោបាយជូនជនរងគ្រោះដោយសារគ្រឿងញៀន ដែលកំពុងស្នាក់នៅក្នុងមណ្ឌលបណ្តោះអាសន្នអប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ចំនួន ៦ កន្លែងគឺ :

  ១- មណ្ឌលបណ្តោះអាសន្ន ឱកាសខ្ញុំ រាជធានីភ្នំពេញ ។

  ២- មណ្ឌលបណ្តោះអាសន្ន របស់បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តព្រះសីហនុ ។

  ៣- មណ្ឌលបណ្តោះអាសន្ន របស់បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តបន្ទាយមានជ័យ ។

  ៤- មណ្ឌលបណ្តោះអាសន្ន របស់បញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្តបាត់ដំបង ។

  ៥- មណ្ឌលបណ្តោះអាសន្ន ពិភពនៃក្តីសង្ឃឹម របស់សាលាខេត្តបាត់ដំបង ។

  ៦- មណ្ឌលបណ្តោះអាសន្ន របស់ស្នងការដ្ឋាននគរបាលខេត្តសៀមរាប ។

  ជូនទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីបន្តនិរន្តរភាពដំណើរការក្នុងការផ្តល់របបឧបត្ថម្ភគោលនយោបាយ ។

### ៣.២. ការកាត់បន្ថយគ្រោះថ្នាក់

***ការងារក្នុងប្រទេស*** *អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ :*

- បានចាត់តាំងថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ដើម្បីរៀបចំកិច្ចប្រជុំត្រៀមរៀបចំការបណ្តុះបណ្តាល នាថ្ងៃទី១៤-១៥/១២/២០១១ នៅសណ្ឋាគារមិត្តភាព, ភ្នំពេញ និងបើកវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីកម្មវិធីយុទ្ធសាស្ត្រប្រកបដោយប្រសិទ្ធភាពក្នុងការកាត់បន្ថយគ្រោះថ្នាក់ ក្នុងចំណោមអ្នកប្រើបំពានគ្រឿងញៀនសម្រាប់មន្ត្រីអនុវត្តច្បាប់ នៅខេត្តកំពង់ចាម ( ១៦-២០/១២/២០១១) ។

- បានចូលរួមជាវាគ្មិន ក្នុងកិច្ចពិភាក្សាយោបល់រវាងរដ្ឋាភិបាល និងសង្គមស៊ីវិល ស្តីពីការសហការអនុវត្តច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព (រៀបចំដោយបណ្តាញអង្គការសង្គមស៊ីវិលមិនមែនរដ្ឋាភិបាលប្រយុទ្ធនឹងជំងឺអេដស៍ ២០/១២/២០១១) ដើម្បីបំភ្លឺរាល់ភាពមន្ទិលនានា ក្នុងការអនុវត្តច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងការអនុវត្តគោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព ។
- បានចាត់ថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ចូលរួមប្រជុំស្តីពី Reprogramming ថវិកាមូលនិធិសកល SSF-HIV ដើម្បីពិភាក្សាលើការអនុវត្តកម្មវិធីម្ទុល/ស៊ីរាំងនៅតាមសហគមន៍ (រៀបចំដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និង កាមរោគ ០៧/១២/២០១១) ។
- បានចូលរួមក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេស ស្តីពីការអប់រំបង្ការជំងឺអេដស៍ក្នុងវិស័យអប់រំ (រៀបចំដោយក្រសួងអប់រំយុវជន និងកីឡា ០២/១២/២០១១) ។ តាមបទបង្ហាញ និងការពិភាក្សា ជាទូទៅឃើញថា នៅកម្ពុជាកំពុងមានការថយចុះនូវចំនួនអ្នកផ្ទុកមេរោគអេដស៍ ប៉ុន្តែមានការកើនឡើងនូវការរួមភេទរបស់យុវវ័យដែលកំពុងសិក្សា និងការថយចុះនូវជំនួយថវិកាពីសហគមន៍អន្តរជាតិ ហើយការធ្វើអង្កេតថ្នាក់ជាតិ មិនទាន់បានធ្វើចំពោះសិស្សជាយុវវ័យថ្នាក់មធ្យមសិក្សា និង ឧត្តមសិក្សា ដែលតម្រូវឱ្យក្រសួងអប់រំយុវជននិងកីឡា ត្រូវធ្វើការផ្សព្វផ្សាយអប់រំពីសុខភាព និងបញ្ហាអេសដី / គ្រឿងញៀន នៅក្នុងគោលដៅសាលារៀន ។
- បានចាត់តាំងក្រុមការងារ របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ដើម្បីរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការប្រមូលទិន្នន័យព័ត៌មានគ្រឿងញៀន/អេដស៍ បានចំនួនពីរវគ្គ នៅខេត្តបាត់ដំបង កាលពីថ្ងៃទី០៥-០៦/១២/២០១១ និងនៅខេត្តកំពង់ចាម កាលពីថ្ងៃទី១៥-១៦/១២/ ២០១១ ដោយប្រើប្រាស់ថវិការបស់មូលនិធិសកលជុំទី៧ ។ សមាសភាពចូលរួមមាន លេខាធិការដ្ឋាន នៃគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត មន្ទីរទេសចរណ៍ មន្ទីរកិច្ចការនារី មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្នងការនគរបាល ចៅសង្កាត់ក្នុងក្រុងកំពង់ចាម អធិការ នគរបាល កងរាជអាវុធហត្ថ និងនគរបាលប៉ុស្តិ៍រដ្ឋបាល (ខេត្តបាត់ដំបង មានមន្ត្រី ២២ រូប-ខេត្តកំពង់ចាម មានមន្ត្រី ២៩ រូប) សរុប ៥១ រូប ។ គោលបំណងគឺ ដើម្បីពង្រឹងសមត្ថភាពក្នុងការប្រមូលទិន្នន័យព័ត៌មានគ្រឿងញៀន/អេដស៍ ដោយមានការធ្វើបទបង្ហាញពី ចំណេះដឹងទូទៅពីគ្រឿងញៀន/អេដស៍, ការប្រមូលទិន្នន័យ និងចុះបញ្ចីក្នុងប្រព័ន្ធទិន្នន័យព័ត៌មានគ្រឿងញៀន និងការធ្វើរបាយការណ៍ និងការបញ្ជូលរបាយការណ៍ ។

## ៤. ការពង្រឹងសមត្ថភាពការងារអនុវត្តច្បាប់

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានសហការសម្របសម្រួលជាមួយអង្គការជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍន៍ ដើម្បីលើកកម្ពស់សមត្ថភាពដល់មន្ត្រីអនុវត្តច្បាប់ ជាអាទិ៍ :

***ការងារក្នុងប្រទេស :***

***អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ***

- បានចាត់តាំងក្រុមការងាររបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ដើម្បីចុះទៅបើកវគ្គបណ្តុះបណ្តាលស្តីពី "ការ

ពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀន" នៅខេត្តចំនួន ២ គឺ :

- ខេត្តបាត់ដំបង ពីថ្ងៃទី ២៤-២៥ ខែវិច្ឆិកា ឆ្នាំ២០១១ មានមន្ត្រីអនុវត្តច្បាប់ចូលរួម ចំនួន ១០០ នាក់ ។
- ខេត្តប៉ៃលិន ពីថ្ងៃទី ២៨-២៩ ខែវិច្ឆិកា ឆ្នាំ២០១១ មានមន្ត្រីអនុវត្តច្បាប់ចូលរួម ចំនួន ១០០ នាក់ ។
- បានចាត់តាំងថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ដើម្បីបន្តកិច្ចសហការជាមួយក្រសួងសុខាភិបាល ក្នុងការរៀបចំផែនការសម្រាប់បណ្តុះបណ្តាលលើការងារគ្រប់គ្រងសារធាតុគីមីផ្សំ និងឱសថដែលមានសារធាតុញៀន នៅតាមបណ្តារាជធានី-ខេត្ត ។
- បាននិងកំពុងបន្តដំណើរការសិក្សាស្រាវជ្រាវ និងប្រមូលព័ត៌មានសារធាតុគីមីផ្សំគ្រឿងញៀន នៅខេត្តតាកែវ ខេត្តកំពង់ចាម និង ខេត្តកំពត ។

**ដោយឡែក** គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន ខេត្តកណ្តាល បានចុះពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់នៅស្រុកជាប់ព្រំដែន ( ស្រុកកោះធំ និង ស្រុកលើកដែក) និងសមាជិកការិយាល័យទំនាក់ទំនងព្រំដែន (BLO) ក្អមសំណ និងជ្រៃធំ និងបានបង្កើតគណៈកម្មការ ដើម្បីអនុវត្តផែនការប្រតិបត្តិត្រួតពិនិត្យគ្រឿងញៀនរបស់ខេត្ត ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានបង្កើនកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគី ជាមួយបណ្តាប្រទេសក្នុងអនុតំបន់ តំបន់ និងអន្តរជាតិ ទទួលបានលទ្ធផលដូចខាងក្រោម :

***ការងារក្នុងប្រទេស*** *អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ :*

- អគ្គលេខាធិការ បានចាត់តាំងឯកឧត្តម គីម ចាន់នី អគ្គលេខាធិការរង ទៅចូលរួមប្រជុំលេខាធិការដ្ឋាននៃក្រុមប្រឹក្សាសហគមន៍នយោបាយ-សន្តិសុខអាស៊ាន (ASEAN Political Secu- rity Community Blueprint) តាមការអញ្ជើញរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ( ទីស្តីការក្រសួងការបរទេស, ២៨/១១/២០១១) ដើម្បីពិភាក្សាលើការអនុវត្តសេចក្តីសម្រេចរបស់កិច្ចប្រជុំកំពូលអាស៊ាន លើកទី១៩ និងកិច្ចប្រជុំក្រុមប្រឹក្សាសហគមន៍នយោបាយ-សន្តិសុខអាស៊ាន លើកទី៦ ពាក់ព័ន្ធនឹងការអនុវត្តផែន ការលំអិតសម្រាប់សហគមន៍នយោបាយ-សន្តិសុខអាស៊ាន ។
- អគ្គលេខាធិការ អ.ជ.ប.គ.ញ បានចាត់តាំង ឯកឧត្តម ឧត្តមសេនីយ៍ឯក លី គីមឡុង អគ្គលេខាធិការរង អ.ជ.ប.គ.ញ ដឹកនាំប្រតិភូកម្ពុជាធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំទ្វេភាគី កម្ពុជា-ថៃ លើកទី៦ ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់គ្រឿងញៀន នៅខេត្តព្រះសីហនុ ព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី ៣0 ខែវិច្ឆិកា ដល់ថ្ងៃទី 0៣ ខែធ្នូ ឆ្នាំ២០១១ ។ កិច្ចប្រជុំបានពិភាក្សា និងឯកភាពគ្នាដូចខាងក្រោម :

  ១- ភាគីថៃនឹងផ្តល់ទូកល្បាត ១ គ្រឿងដល់ខេត្តព្រះវិហារ ។

  ២- ភាគីថៃនឹងបន្តផ្តល់ការបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់កម្ពុជា នៅបណ្តាខេត្តជាប់ព្រំដែន កម្ពុជា-ថៃ ចំនួន ២៤ រូប សម្រាប់ឆ្នាំក្រោយ នៅខេត្តរ៉ាក់យ៉ង ប្រទេសថៃ និងឯកភាពបញ្ជូនគ្រូឯកទេសមកធ្វើការបណ្តុះបណ្តាលនៅកម្ពុជាផងដែរ ។

៣- ឯកភាពរៀបចំប្រជុំប្តូរវេនរវាងថ្នាក់ស្រុក និងខេត្តជាប់ព្រំដែន និងរៀបចំប្រជុំការិយាល័យទំនាក់ទំនងព្រំដែន (BLO) នៅតាមព្រំដែន ។

៤- ភាគីថៃឯកភាពផ្តល់ការបណ្តុះបណ្តាលជំនាញមន្ទីរពិសោធន៍ ដល់មន្ត្រីនគរបាលខេត្តបាត់ដំបង ចំនួន ៣ រូប នៅខេត្តបាត់ដំបង នាខែមករា ឆ្នាំ២០១២ ។

៥- ភាគីថៃនឹងផ្តល់ការបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សាសម្រាប់មន្ត្រីត្រួតពិនិត្យគ្រឿងញៀន ទាំងលើផ្នែកអនុវត្តច្បាប់ ការប្រមូលទិន្នន័យព័ត៌មាន ការវិភាគគ្រឿងញៀន ការគ្រប់គ្រងមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដោយលើកគម្រោងសម្រាប់រយៈពេល ៣ ឆ្នាំ និងចែកចេញជាបីដំណាក់កាលគឺ ទី១. ភាគីថៃត្រូវចុះមកធ្វើការសិក្សា និងប្រមូលព័ត៌មានឱ្យបានលំអិតពីតម្រូវការចាំបាច់របស់កម្ពុជា ទី២. រៀបចំសិក្ខាសាលាមួយដោយមានកម្ពុជាចូលរួម ដើម្បីធ្វើការវិភាគលើតម្រូវការនេះ និងរៀបចំឱ្យមានកម្មវិធីទស្សនកិច្ចសិក្សាលើការងារព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅប្រទេសថៃ ទី៣. នឹងរៀបចំជាសិក្ខាសាលាមួយទៀត ស្តីពីការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

៦- ភាគីថៃបានផ្តល់ឯកសារពាក់ពន្ធ័នឹងការងារផ្សព្វផ្សាយអប់រំ សម្រាប់ក្រុមកាយឫទ្ធិកម្ពុជា ។

៧- ភាគីថៃនឹងពិភាក្សាជាមួយស្ថាប័នជំនាញ តាមការស្នើរបស់កម្ពុជាឱ្យជួយជួសជុលម៉ាស៊ីនវិភាគគ្រឿងញៀនប្រភេទ GC-MS ។

៨- ភាគីទាំងពីរ បានឯកភាពរៀបចំកិច្ចប្រជុំលើកទី៧ នៅហួហ៊ិន ប្រទេសថៃ ដែលកាលបរិច្ឆេទនឹងជូនដំណឹងនៅពេលក្រោយ ។

- អគ្គលេខាធិការ បានចាត់តាំងឯកឧត្តម គីម ចាន់នី អគ្គលេខាធិការរង អ.ជ.ប.គ.ញ ទៅចូលរួមកិច្ចប្រជុំអន្តរក្រសួង ដើម្បីរៀបចំខ្លឹមសារកិច្ចប្រជុំគណៈកម្មការចម្រុះសហប្រតិបត្តិការទ្វេភាគី កម្ពុជា- ថៃ លើកទី៨ កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១១ នៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ។
- អគ្គលេខាធិការ បានចាត់តាំងឯកឧត្តម មាស វីរិទ្ធ អគ្គលេខាធិការរង ទៅចូលរួមកិច្ចប្រជុំក្រុមការងារអន្តរគាំទ្រ **"លើវិធានការក្នុងការកសាងទំនុកចិត្ត និងការបង្ការផ្នែកការទូត"** ដើម្បីពិភាក្សាលើការងារសន្តិសុខ និងវិស័យកិច្ចសហប្រតិបត្តិការក្រោមក្របខណ្ឌវេទិកាអាស៊ាន Inter-Sessional Support Group Meeting on Confidence-Building Measures and Preventive Diplomacy (សណ្ឋាគារភ្នំពេញ, ០៧-០៩/១២/២០១១) ។
- អគ្គលេខាធិការ អ.ជ.ប.គ.ញ បានស្នើសុំគោលការណ៍ពីឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ ដើម្បីរក្សាសុពលភាពអនុស្សារណៈនៃការយោគយល់គ្នា (MOU) ស្តីពីការប្រយុទ្ធប្រឆាំងការជួញដូរគ្រឿងញៀន និងការអភិវឌ្ឍន៍កិច្ចសហប្រតិបត្តិការនគរបាល ដែលបានចុះហត្ថលេខាកាលពីឆ្នាំ២០០៩ រវាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងនគរបាលសហពន្ធ័អូស្ត្រាលី ។
- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានបូកសរុបរបាយការណ៍ ស្តីពីការអនុវត្តផែនការលម្អិតក្រុមប្រឹក្សាសហគមន៍សង្គម-វប្បធម៌អាស៊ាន និងបានបញ្ជូនទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

***ការងារក្រៅប្រទេស*** *អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ :*

- បានចាត់តាំងឯកឧត្តម **គីម ចាន់នី** អគ្គលេខាធិការរង អ.ជ.ប.គ.ញ ទៅចូលរួមកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលចម្រុះនៃតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា-ឡាវ-វៀតណាម (CLV) និងកិច្ចប្រជុំពាក់ពន្ធ័ កាលពីថ្ងៃទី ០៦-១០/១២/២០១១ នៅខេត្តអាត់តាពឺ ប្រទេសឡាវ ។ កិច្ចប្រជុំបានផ្តោតសំខាន់ទៅលើលទ្ធផលនៃកិច្ចប្រតិបត្តិការ ជាពិសេសចំពោះការអនុវត្តអនុស្សារណៈស្តីពីនយោបាយអនុគ្រោះពិសេស និងការអនុវត្តផែនការមេសម្រាប់តំបន់ត្រីកោណ ពីឆ្នាំ២០១០-២០២០ ដោយបានសង្កត់ធ្ងន់និងឯកភាពគ្នាលើ ១២ ចំណុច ហើយក្នុងនោះមាន ២ ចំណុច ដែលពាក់ពន្ធ័នឹងបញ្ហាគ្រឿងញៀន គឺ :
  - ចំណុចទី៧. បានឯកភាពបង្កើតប្រព័ន្ធទំនាក់ទំនងទាន់ហេតុការណ៍ តាមកម្រិតក្នុងប្រទេសនីមួយៗ ដើម្បីសហការបង្រ្កាបការរត់ពន្ធគ្រឿងញៀន ការជួញដូរមនុស្ស អំពើភេរវកម្មឆ្លងដែន ដ៏ដូចជាដើម្បីស្នើសុំជំនួយសង្គ្រោះបន្ទាន់លើសេវាសុខភាព ។
  - ចំណុចទី៨. បានឯកភាពពិនិត្យលទ្ធភាពក្នុងការដំឡើងថ្នាក់ច្រកទ្វារព្រំដែន ពីកម្រិតជាតិទៅជាកម្រិតតំបន់ ពីកម្រិតតំបន់ ទៅជាកម្រិតអន្តរជាតិ និងការបង្កើតច្រកទ្វារថ្មីបន្ថែមទៀត ប្រសិនបើមានការចាំបាច់ ។
- បានចាត់តាំង ឯកឧត្តម គីម ចាន់នី អគ្គលេខាធិការរង អ.ជ.ប.គ.ញ ចូលរួមប្រជុំគណៈកម្មាធិការព្រំដែនទូទៅកម្ពុជា-ថៃ លើកទី៨ ក្រោមអធិបតីភាព ឯកឧត្តម នាយឧត្តមសេនីយ៍ ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ កាលពីថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១១ នៅ Sofitel Pouketra Hotel ។

***-ការងារផ្សេងៗ***

ដើម្បីបំពេញឱ្យការអនុវត្តទិសដៅសកម្មភាពពហុវិស័យខាងលើ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានអនុវត្តការងារមួយចំនួនទៀត មានដូចខាងក្រោម :

**១.** ក្រុមការងាររៀបចំច្បាប់ និងលិខិតបទដ្ឋានស្តីពីការត្រួតពិនិត្យគ្រឿងញៀន បានចូលរួមបំភ្លឺដល់គណៈកម្មការទី៤នៃព្រឹទ្ធសភាលើអត្ថបទច្បាប់ស្តីពី ការត្រួតពិនិត្យគ្រឿងញៀន កាលពីថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១១ នៅមន្ទីរព្រឹទ្ធសភា ។

**២.** អគ្គលេខាធិការ បានចាត់តាំងឯកឧត្តម **មាស វីរិទ្ធ** អគ្គលេខាធិការរង អ.ជ.ប.គ.ញ ទៅចូលរួមក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១១ និងទិសដៅការងារឆ្នាំ២០១២ របស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន ខេត្តបាត់ដំបង កាលពីថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ២០១១ និងកិច្ចប្រជុំបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខេត្តកំពង់ស្ពឺ ។

**៣.** បានចូលរួមប្រជុំដើម្បីពិនិត្យ និងឱ្យយោបល់លើអត្ថបទច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១១ នៅមន្ទីរព្រឹទ្ធសភា (ដឹកនាំដោយ ឯកឧត្តម **ឧបនាយករដ្ឋមន្ត្រី** ប្រធាន អ.ជ.ប.គ.ញ) ។

**៤.** បានចូលរួមក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១១ និងទិសដៅការងារឆ្នាំ២០១២ របស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១១ មានអ្នកចូលរួមសរុប ៣៥០ នាក់ (ដឹកនាំដោយ ឯកឧត្តម **ឧបនាយករដ្ឋមន្ត្រី** ប្រធាន អ.ជ.ប.គ.ញ) ។

៥. គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តកណ្ដាល បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១១ និងទិសដៅការងារ ឆ្នាំ២០១២ កាលពីថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ ២០១១ ដែលមានអ្នកចូលរួម ៣២៥ នាក់ (ដឹកនាំដោយឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តកណ្ដាល) ។

៦. អគ្គលេខាធិការ បានចាត់តាំងឯកឧត្តម ឧត្តមសេនីយ៍ឯក **លី គឹមឡុង** អគ្គលេខាធិការរង អ.ជ.ប.គ.ញ ទៅចូលរួមក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១១ និងទិសដៅការងារឆ្នាំ២០១២ របស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តស្វាយរៀង កាលពីថ្ងៃទី២០/១២/២០១១ ដែលមានអ្នកចូលរួមសរុបចំនួន ២៥៥ នាក់ ។

៧. អគ្គលេខាធិការ បានចាត់តាំងឯកឧត្តម **គឹម ចាន់នី** អគ្គលេខាធិការរង អ.ជ.ប.គ.ញ ទៅចូលរួមប្រជុំតាមការអញ្ជើញរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីពិភាក្សាលើរបាយការណ៍ស្ដីពីការអនុវត្តផែនការលំអិត របស់ក្រុមប្រឹក្សាសហគមន៍សង្គម-វប្បធម៌អាស៊ាន (ក.ស.វ.អ) កាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១១ ដើម្បីត្រៀមលក្ខណៈធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលអាស៊ាន ឆ្នាំ២០១២ ។

៨. មជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន បានសរសេរបញ្ចប់ទាំងស្រុងនូវកម្មវិធីគ្រប់គ្រងប្រព័ន្ធទិន្នន័យព័ត៌មានគ្រឿងញៀនតាមម៉ាស៊ីនកុំព្យូទ័រ ។ តាមស្មារតីរបស់អង្គប្រជុំ កាលពីថ្ងៃទី១៧/៨/២០១១ គឺបានប្ដូរឈ្មោះពី :

- ទម្រង់ទិន្នន័យប្រឆាំងបទល្មើសគ្រឿងញៀន ទៅជា **ទម្រង់ទិន្នន័យតាមគោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន** ។
- ទម្រង់ទិន្នន័យអ្នកទៅទទួលសេវានៅមណ្ឌលស្ដារនីតិសម្បទា ទៅជា **ទម្រង់ទិន្នន័យអ្នកចូលទៅរកសេវានៅមន្ទីរពេទ្យ / មណ្ឌលសុខភាព** ។
- ទម្រង់ទិន្នន័យអ្នកទៅទទួលសេវានៅមណ្ឌលស្ដារនីតិសម្បទា ទៅជា **ទម្រង់ទិន្នន័យអ្នកចូលទៅរកសេវាព្យាបាលនៅមណ្ឌលបណ្ដោះអាសន្នសម្រាប់ការអប់រំ ព្យាបាល និងស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀន** ។

## III. ការសន្និដ្ឋាន និងវាយតម្លៃ

ដោយមានការចូលរួមពីគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ កងកម្លាំងប្រដាប់អាវុធគ្រប់សមាសភាព និងគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត និង វិស័យឯកជន នានា ធ្វើឱ្យការអនុវត្តយុទ្ធសាស្ត្រពហុវិស័យទាំង ៥ ក្នុងការត្រួតពិនិត្យគ្រឿងញៀន ទទួលបានលទ្ធផលល្អប្រសើរ ។ ប៉ុន្តែក៏នៅសង្កេតឃើញមានចំណុចខ្វះខាតមួយចំនួនផងដែរ ជាអាទិ៍ :

-ការងារកាត់បន្ថយតម្រូវការគ្រឿងញៀន យើងធ្វើបានច្រើនជាមួយក្រុមយុវជននៅក្នុងប្រព័ន្ធអប់រំ ប៉ុន្តែចំពោះក្រុមសិស្សដែលគេចមិនចូលសាលារៀន និងក្រុមដែលងាយប្រឈមខ្ពស់នឹងគ្រោះថ្នាក់ផ្សេងទៀត យើងនៅតែមិនទាន់មានឱកាសអប់រំពួកគេដោយផ្ទាល់ ឱ្យបានច្រើនជាងការអប់រំជាប្រយោលនៅឡើយ ។

-ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន ក៏ពិនិត្យឃើញថា មន្ត្រីអនុវត្តច្បាប់នៅមូលដ្ឋានបានខិតខំបង្ក្រាបយ៉ាងសកម្ម ធ្វើឱ្យការងារបង្ក្រាបបទល្មើសគ្រឿងញៀនទទួលបានលទ្ធផលល្អជាងខែមុន ប៉ុន្តែក្រុមឈ្មួញនៅតែបន្តការព្យាយាមធ្វើសកម្មភាពចរាចរ ចែកចាយ ជួញដូរ តាមរូបភាពតូចៗ និងតាមគ្រប់លទ្ធភាពដែលអាចធ្វើទៅបាន ។

-ការងារព្យាបាលនិងស្តារនីតិសម្បទា ជាពិសេសកម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ នៅតាមបណ្តាខេត្តជាប់ព្រំដែន កម្ពុជា-ឡាវ ដែលបានដាក់ចេញនៅក្នុងទិសដៅកាលពីខែកន្លងទៅ ក៏ទើបតែរៀបចំអនុវត្តនៅឡើយ ។

-ការពង្រឹងសមត្ថភាពការងារអនុវត្តច្បាប់ យើងក៏បានចុះទៅធ្វើការបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តជាច្រើនខេត្ត និងជាបន្តបន្ទាប់ ប៉ុន្តែក៏នៅមានសំណូមពរមួយចំនួន ដូចជា ការស្នើសុំបណ្តុះបណ្តាលឱ្យកាន់តែយល់ដឹងបានស៊ីជម្រៅពីប្រភេទសារធាតុគីមីផ្សំដែលគេអាចយកទៅផលិតជាគ្រឿងញៀនបាន, ការយល់ដឹងពីអត្តសញ្ញាណគ្រឿងញៀន, ការយល់ដឹងពីចរិតអ្នកញៀនទៅតាមប្រភេទគ្រឿងញៀននីមួយៗ ដើម្បីងាយស្រួលកត់សំគាល់និងតាមដាន រួមទាំងការស្នើសុំឱ្យស្ថាប័នដែលមានសមត្ថកិច្ចពាក់ពន្ធ័ត្រូវផ្តល់ព័ត៌មានជាមុនដល់អាជ្ញាធរមូលដ្ឋាន នៅមុនពេលដែលទណ្ឌិតត្រូវបានដោះលែងពីពន្ធនាគារឱ្យវិលមកលំនៅដ្ឋានដើមវិញ ។

-កិច្ចសហប្រតិបត្តិការអន្តរជាតិ យើងក៏បានខិតខំពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការបានច្រើនជាមួយបណ្តាប្រទេស និងអង្គការជាដៃគូអភិវឌ្ឍន៍ ប៉ុន្តែគម្រោងមួយចំនួននៅមានភាពយឺតយ៉ាវក្នុងការផ្តល់ការគាំទ្រដល់កម្ពុជា ។

## IV. ទិសដៅសកម្មភាពការងារត្រួតពិនិត្យគ្រឿងញៀន ខែ មករា ឆ្នាំ ២០១២

ដើម្បីធ្វើឱ្យមាននិរន្តរភាពការងារពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នឹងបន្តអនុវត្តនូវទិសដៅសកម្មភាពមួយចំនួនដូចខាងក្រោម :

### ១. ការកាត់បន្ថយតម្រូវការគ្រឿងញៀន

១.១. អគ្គលេខាធិការដ្ឋាន នឹងបន្តអញ្ជើញគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តគោលដៅ ដើម្បីផ្តល់កិច្ចសម្ភាសន៍នៅស្ថានីយទូរទស្សន៍ CTN ស្តីពីសកម្មភាពនិងលទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនរបស់ខេត្ត ។

១.២. ត្រៀមរៀបចំផែនការសកម្មភាព និងគម្រោងថវិកាចំណាយសម្រាប់ការរៀបចំវេទិកា សំណួរ-ចម្លើយសម្រាប់សិស្ស និស្សិត វិទ្យាល័យ និងមហាវិទ្យាល័យ ដើម្បីបង្កើនចំណេះដឹងពីបញ្ហាគ្រឿងញៀន តាមប្រពន្ធ័ផ្សព្វផ្សាយឱ្យបានកាន់តែទូលំទូលាយ ។

១.៣. បន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័ននានា ដើម្បីអនុវត្តកម្មវិធីផ្សព្វផ្សាយអប់រំ លើកកម្ពស់ការយល់ដឹងជាសាធារណៈពីគ្រឿងញៀន តាមប្រពន្ធ័ផ្សព្វផ្សាយរដ្ឋ និង ឯកជន និងបន្តកិច្ចសហការជាមួយក្រសួង-ស្ថាបន័នានា ក្នុងការចុះទៅបណ្តុះបណ្តាលផ្សព្វផ្សាយអប់រំផ្ទាល់នៅតាមសហគមន៍ជាតិ រួមទាំងបន្តជំរុញរាជធានី-ខេត្ត ដើម្បីអនុវត្តកម្មវិធីផ្សព្វផ្សាយអប់រំជាប្រចាំ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

### ២. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន

២.១. បន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័នមានសមត្ថកិច្ច គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត និងអង្គការ UNODC តាមរយៈគម្រោង PATROL ដើម្បីសម្របសម្រួលក្នុងការរៀបចំបង្កើតស្ថានីយសម្រាប់សម្ភាសន៍ទេសន្តរប្រវេសន៍នៅច្រកទ្វារអន្តរជាតិ**ចាំយាម**(ខេត្តកោះកុង) និងច្រកទ្វារអន្តរជាតិ**ប៉ោយប៉ែត** (ខេត្តបន្ទាយមានជ័យ) ។

២.២. បន្តកិច្ចសហការជាមួយអង្គការ UNODC អនុតំបន់ ដើម្បីរៀបចំផែនការសកម្មភាពគម្រោង PATROL

សម្រាប់ឆ្នាំ២០១២ និង រៀបចំពិធីប្រគល់-ទទួល មធ្យោបាយ សម្ភារការិយាល័យទំនាក់ទំនងព្រំដែន (BLO) ច្រកទ្វារអន្តរជាតិ ភ្នំដិន (ខេត្តតាកែវ) ។

២.៣. ត្រៀមរៀបចំបណ្តុះបណ្តាលជំនាញត្រួតពិនិត្យគ្រឿងញៀនតាមប្រពន្ធ័កុំព្យូទ័រ (CBT) សម្រាប់មន្ត្រីអនុវត្តច្បាប់ ដែលប្រចាំការនៅតាមគ្រប់ការិយាល័យទំនាក់ទំនងព្រំដែន ។

២.៤. បន្តកិច្ចសហការជាមួយអង្គការ UNODC ក្នុងការរៀបចំបង្កើតការិយាល័យទំនាក់ទំនងព្រំដែន (BLO) សមុទ្រ ។

២.៥. បន្តកិច្ចសហការសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ពន្ធ័ ដើម្បីប្រមូលទិន្នន័យស្តីពីការនាំចូល នាំចេញ និងប្រើប្រាស់សារធាតុគីមីផ្សំ ។

២.៦. បន្តកិច្ចសហការជាមួយក្រសួងសុខាភិបាល ដើម្បីពង្រឹងការគ្រប់គ្រងសារធាតុ និងឱសថ ដែលមានជាតិញៀន និងរៀបចំផែនការសកម្មភាពសម្រាប់ចុះបណ្តុះបណ្តាលការងារគ្រប់គ្រងសារធាតុគីមី និងឱសថដែលមានជាតិញៀន នៅតាមបណ្តារាជធានី-ខេត្ត ។

២.៧. សហការជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បរៀបចំផែនការគ្រប់គ្រងសារធាតុគីមីសម្រាប់ឆ្នាំ ២០១២ ។

## ៣. ការងារព្យាបាល ស្តារនីតិសម្បទា និងការកាត់បន្ថយគ្រោះថ្នាក់

៣.១. បន្តកិច្ចសហការសម្របសម្រួលជាមួយក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសង្គម-កិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីតាមដានសំណើសុំជំនួយសាងសង់មជ្ឈមណ្ឌលជាតិ ព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដែលបានដាក់ស្នើសុំទៅភាគីវៀតណាម ។

៣.២. បន្តសហការសម្របសម្រួលជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការតាមដានការអនុវត្តកម្មវិធីប្រចាំថ្ងៃនៅតាមមណ្ឌលបណ្តោះអាសន្នអប់រំ ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនរបស់រដ្ឋនិងឯកជន ។

៣.៣. បន្តកិច្ចសហការជាមួយក្រសួងសុខាភិបាល ដើម្បីជំរុញការរៀបចំបង្កើតសេវាសុខភាពផ្លូវចិត្តនិងគ្រឿងញៀននៅ ខេត្តស្ទឹងត្រែង និង ខេត្តក្រចេះ ដើម្បីចូលរួមអនុវត្តផែនការសកម្មភាពរបស់គណៈកម្មការចម្រុះដោះស្រាយបញ្ហាគ្រឿងញៀននៅខេត្តជាប់ព្រំដែនឡាវ ។

៣.៤. បន្តកិច្ចសហការសម្របសម្រួលជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការរៀបចំផ្ទេររបបឧបត្ថម្ភគោលនយោបាយ ជូនជនរងគ្រោះដោយសារគ្រឿងញៀននៅមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋ ចំនួន ៦ កន្លែង ។

## ៤. ការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៏ច្បាប់

៤.១. ត្រៀមបើកវគ្គបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ នៅខេត្តពោធិ៍សាត់ ស្តីពី "ការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀន និងការកាត់បន្ថយគ្រោះថ្នាក់ដល់មន្ត្រីអនុវត្ត" នៅថ្ងៃទី ២៨-៣០ ខែធ្នូ ឆ្នាំ២០១១ និងនៅខេត្តកំពង់ចាម នាថ្ងៃទី១៦-២០ ខែមករា ឆ្នាំ២០១២ ។

៤.២. បន្តកិច្ចសហការសម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំយន្តការគ្រប់គ្រងនិងត្រួតពិនិត្យការចរាចរ និងការប្រើប្រាស់សារធាតុគីមីផ្សំគ្រឿងញៀន ។

៤.៣. បន្តការរៀបចំកែសម្រួល តួនាទី ភារកិច្ច សមាសភាព របស់ការិយាល័យទំនាក់ ទំនងព្រំដែន (BLO) ទាំង ១៤ កន្លែង នៅតាមបណ្តោយព្រំដែន កម្ពុជា-ថៃ កម្ពុជា-វៀតណាម និង កម្ពុជា-ឡាវ ។

៤.៤. បន្តការរៀបចំសមាសភាព គណៈកម្មការប្រឹក្សាយោបល់គម្រោង (C-PAC) នៃគម្រោងភាពជាដៃគូនៃមន្ត្រីអនុវត្តក្នុងតំបន់ប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន (PATROL) ។

៤.៥. រៀបចំកម្មវិធីពិភាក្សាជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត លើលទ្ធផលបឋមនៃការសិក្សា និងប្រមូលព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រងការចរាចរ និងប្រើប្រាស់សារធាតុគីមីផ្សំ និងវិធានការសម្រាប់អនុវត្តបន្ត ។

៤.៦. បន្តពិភាក្សាជាមួយក្រសួងសុខាភិបាល និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ពាក់ព័ន្ធនឹងការលើកកម្ពស់ការគ្រប់គ្រងការចរាចរ និងប្រើប្រាស់សារធាតុគីមីផ្សំ ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ

៥.១. ត្រៀមជួបពិភាក្សាការងារជាមួយលោក ហ្គារី ហាវីសុន តំណាងស្ថាប័នប៉ូលីសកាណាដា មកធ្វើទស្សនកិច្ចលើកម្មវិធីព្យាបាលដោយផ្អែកលើសហគមន៍ នៅខេត្តបន្ទាយមានជ័យ ។

៥.២. ត្រៀមរៀបចំកិច្ចប្រជុំដើម្បីត្រៀមប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់ ប្រទេសមហាអនុតំបន់ទន្លេមេគង្គ (ប្រទេសហត្ថលេខីលើ MOU ឆ្នាំ១៩៩៣) ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន នាខែកុម្ភៈ ឆ្នាំ ២០១២ នៅកម្ពុជា ។

៥.៣. កិច្ចប្រជុំជាមួយអ្នកសម្របសម្រួលគម្រោង UNODC ដើម្បីត្រៀមរៀបចំកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ប្រទេសមហាអនុតំបន់ទន្លេមេគង្គ (ប្រទេសហត្ថលេខីលើ MOU ឆ្នាំ១៩៩៣) ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ។

ក្រៅពីទិសដៅសកម្មភាពការងារខាងលើ អគ្គលេខាធិការដ្ឋាននឹងបន្តអនុវត្តការងារមួយចំនួនទៀត ដើម្បីបំពេញឱ្យយុទ្ធ-សាស្ត្រពហុវិស័យទាំង ៥ ដូចជា :

- បន្តរៀបចំបកប្រែច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ជាភាសាបរទេស, រៀបចំបោះពុម្ពច្បាប់, រៀបចំសិក្ខាសាលាជាតិ, រៀបចំព្រះរាជក្រឹត្យ, អនុក្រឹត្យ, ប្រកាស នានា ដែលពាក់ព័ន្ធនឹងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ស្ថាប័ននីតិប្បញ្ញត្តិ បានអនុម័តយល់ព្រមហើយ ។
- ត្រៀមចូលរួមប្រជុំបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១១ និងទិសដៅការងារឆ្នាំ ២០១២ របស់បណ្តាខេត្តនៅព្រំដែនភាគឦសាន ។
- បន្តជំរុញការរៀបចំផែនការជាតិ៥ឆ្នាំ លើកទី២ (២០១១-២០១៥) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

- ត្រៀមពិនិត្យផែនការយុទ្ធសាស្ត្រជាតិឆ្លើយតបចំពោះការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ ដែលពាក់ពន្ធ័នឹងការប្រើបំពានគ្រឿងញៀន ។
- ត្រៀមរបាយការណ៍វាយតម្លៃលើការអនុវត្តកម្មវិធីម្ហូល/ស៊ីរ៉ាំង របស់អង្គការមិត្តសម្លាញ់ ។
- ត្រៀមរៀបចំសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១១ និងទិសដៅការងារឆ្នាំ២០១២ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅចុងខែកុម្ភៈ ឆ្នាំ២០១២ និងធ្វើការវាយតម្លៃពីសភាពការណ៍ លទ្ធផលការងារដែលបានធ្វើ និងមិនទាន់បានធ្វើ ចំណុចខ្លាំង និងចំណុចខ្សោយ ។
- បន្តជំរុញការរៀបចំសាលាបៃតង ដើម្បីផ្សព្វផ្សាយ និងអនុវត្តនៅឆ្នាំ២០១២ ខាងមុខ ។

**អគ្គលេខាធិការ**

**ចម្លងជូន**

-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

-ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អ.ជ.ប.គ.ញ

-ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន

"ដើម្បីជូនជ្រាប"

-ក្រសួង សមាជិក អ.ជ.ប.គ.ញ

-ក្រសួងផែនការ

-អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ

-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត

-នាយកដ្ឋាន សរុប នៃទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីមុខការ"

-ឯកសារ

*សកម្មភាពសំខាន់ៗ*

*ក្នុងការដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ខែ ធ្នូ ឆ្នាំ២០១១*

| *ល.រ* | *ខ្លឹមសារ និង គោលដៅ* |
|---|---|
| *១* | *ការណែនាំឲ្យអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ចូលរួមប្រជុំលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាសហគមន៍នយោបាយ-សន្តិសុខអាស៊ាន ASEAN Political Security Community Blueprint នៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ (២៨ វិច្ឆិកា ២០១១)* |
| *២* | *ការណែនាំឲ្យអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ចូលរួមប្រជុំ Inter-Sessional Support Group Meeting on Confidence-Building Measures and Preventive Diplomacy នៅថ្ងៃទី០៧-០៨/១២/២០១១ នៅសណ្ឋាគារភ្នំពេញ* |
| *៣* | *ការណែនាំឲ្យចូលរួមកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលចម្រុះ នៃតំបន់ត្រីកោណអភិវឌ្ឍន៍ កម្ពុជា ឡាវ វៀតណាម (**CLV**) និងកិច្ចប្រជុំ* |

| | |
|---|---|
| | ពាក់ពន្ធ័ នៅប្រទេសឡាវ (ដឹកនាំដោយឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អ.ជ.ប.គ.ញ ថ្ងៃទី ០៦-១០ ខែធ្នូ ឆ្នាំ២០១១) |
| ៤ | ការណែនាំឲ្យអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ រៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីនៅខេត្តបាត់ដំបង ស្តីពីការប្រមូលទិន្នន័យព័ត៌មានគ្រឿងញៀន / អេដស៍ (០៥-០៦/១២/២០១១) |
| ៥ | បានណែនាំឲ្យអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ចូលរួមក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន របស់ខេត្តបាត់ដំបង (ថ្ងៃទី ១៣ / ១២ / ២០១១) និងខេត្តស្វាយរៀង (ថ្ងៃទី ២០ / ១២/ ២០១១) |
| ៦ | ការណែនាំឲ្យអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រៀមទទួលប្រតិភូស្ថាប័នប៉ូលីសកាណាដា មកបំពេញទស្សនកិច្ចផ្លូវការលើការងារព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ នៅខេត្តបន្ទាយមានជ័យ |
| ៧ | ការណែនាំឲ្យអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រៀមរៀបចំកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់ទ្វេភាគី កម្ពុជា-ថៃ លើកទី៦ ស្តីពីកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់គ្រឿងញៀន ដែលនឹងប្រព្រឹត្តទៅនៅខេត្តព្រះសីហនុ, ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី៣០ ខែវិច្ឆិកា -០៣ ខែធ្នូ ឆ្នាំ២០១១ |
| ៨ | បានណែនាំឲ្យបន្តការរៀបចំបកប្រែច្បាប់ បោះពុម្ពច្បាប់ រៀបចំសិក្ខាសាលាផ្សព្វផ្សាយច្បាប់ រៀបចំព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ដែលពាក់ព័ន្ធនឹងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ |

## សកម្មភាពផ្សព្វផ្សាយអប់រំ របស់រាជធានី-ខេត្ត ប្រចាំខែ ធ្នូ ឆ្នាំ២០១១

| ល.រ | ឈ្មោះស្ថាប័ន | ខ្លឹមសារផ្សព្វផ្សាយ | អ្នកចូលរួម |
|---|---|---|---|
| ១ | អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ | -បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី ការប្រមូលទិន្នន័យព័ត៌មានគ្រឿងញៀន / អេដស៍ ដល់មន្ត្រីពាក់ពន្ធ័ចំណុះខេត្តបាត់ដំបង សរុបចំនួន **<u>២២</u>** រូប<br>-បានរៀបចំវគ្គបណ្តុះបណ្តាល<br>-បានអញ្ជើញគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តតាកែវ ដើម្បីផ្តល់បទសម្ភាសន៍នៅស្ថានីយទូរទស្សន៍ ស៊ី.ធី.អិន ស្តីពីលទ្ធផលនិងការទទួលខុសត្រូវលើការងារត្រួតពិនិត្យគ្រឿងញៀនរបស់ខេត្ត | ២២ នាក់ |
| ២ | កណ្តាល | -បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ ២០១១ និងទិសដៅការងារ ឆ្នាំ ២០១២ មានអ្នកចូលរួម **<u>៣២៩</u>** នាក់ | ៣២៩ នាក់ |
| ៣ | ព្រះវិហារ | -អាជ្ញាធរស្រុកសង្គមថ្មី ស្រុករវៀង ស្រុកជ័យសែន ស្រុកត្បែងមានជ័យ បានផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងផលប៉ះពាល់នៃគ្រឿងញៀន ចំនួន ៧ លើក = **<u>១.០៨៥</u>** នាក់ / ស្រី ៦១៤ នាក់<br>-សប្តាហ៍ទី១ ខែធ្នូ ស្រុកត្បែងមានជ័យ និង ស្រុករវៀង ផ្សព្វផ្សាយពីផលប៉ះពាល់នៃគ្រឿងញៀន ៦ លើក មានអ្នកចូលរួម **<u>៥១៧</u>** នាក់ / ស្រី ៣៣៤ នាក់ | ១.៦០២ នាក់ |
| ៤ | កែប | -អធិការដ្ឋាននគរបាលស្រុកដំណាក់ចង្អើរ ខេត្តកែប បានបញ្ជ្រាបការងារផ្សព្វផ្សាយអប់រំ ពីគ្រោះថ្នាក់នៃគ្រឿងញៀន ក្នុងឱកាសផ្សព្វផ្សាយគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព ១ លើក = <u>៤៤</u> នាក់ / ស្រី ១៤ នាក់ | ៤៤ នាក់ |
| ៥ | តាកែវ | -អាជ្ញាធរស្រុកបុរីជលសារ និង ស្រុកកោះអណ្តែត ផ្សព្វផ្សាយអំពីគ្រោះថ្នាក់នៃគ្រឿងញៀន ២ លើក មានអ្នកចូលរួម **<u>៧៥</u>** នាក់ / ស្រី ២០ នាក់ | ៧៥ នាក់ |
| ៦ | ស្វាយរៀង | -គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន បានរៀបចំសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១១ និងទិសដៅការងារឆ្នាំ ២០១២ មានអ្នកចូលរួម **<u>២៩៥ នាក់</u>** / ស្រី ២២ នាក់ | ២៩៥ នាក់ |
| ៧ | បាត់ដំបង | -នគរបាលស្រុកថ្មគោល បានចុះផ្សព្វផ្សាយអំពីគ្រោះថ្នាក់នៃគ្រឿងញៀន និងមេរោគអេដស៍ មានប្រជាពលរដ្ឋចូលរួម **<u>១១៧</u>** នាក់ (ស្រី ៥១ នាក់)<br>-នគរបាលស្រុកថ្មគោល បានចុះផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន ចំនួន ៦ លើក មានអ្នកចូលរួមចំនួន <u>៨០៤</u> នាក់ / ស្រី ២៥០ នាក់ | ៩២១ នាក់ |
| សរុប | | | **៣.២៨៨ នាក់** |

## បទល្មើសគ្រឿងញៀនដែលបង្ក្រាប ក្នុងខែ ធ្នូ ឆ្នាំ២០១១

| លរ | អង្គភាពបង្ក្រាប | សរុបរួម | | | ដឹកជញ្ជូន ជួញដូរ | | | ផលិត | | | ដាំដុះ ចម្រាញ់ប្រេងរុក្ខ. | | | ប្រើប្រាស់គ្រឿងញៀន | | | ចាប់តាមដីកា | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ករណី | នាក់ | ស្រី | ករណី | នាក់ | ស្រី | ករណី | នាក់ | ស្រី | ករណី | នាក់ | ស្រី | ករណី | នាក់ | ស្រី | ចំនួនដីកា | នាក់ | ស្រី |
| 1 | មន្ទីរប្រឆាំង គ្រ.ញ | **4** | **11** | **3** | 4 | 10 | 3 | | | | | | | | | | 1 | 1 | 0 |
| 2 | ន.ប ភ្នំពេញ | **12** | **19** | **2** | 11 | 17 | 2 | | | | | | | 1 | 2 | 0 | | | |
| 3 | ន.ប កណ្តាល | **1** | **1** | **0** | 1 | 1 | 0 | | | | | | | | | | | | |
| 4 | ន.ប កំពង់ស្ពឺ | **1** | **5** | **1** | 1 | 5 | 1 | | | | | | | | | | | | |
| 5 | ន.ប កំពង់ឆ្នាំង | **1** | **2** | **0** | 1 | 2 | 0 | | | | | | | | | | | | |
| 6 | ន.ប កំពង់ចាម | **10** | **28** | **6** | 7 | 23 | 6 | | | | | | | 3 | 5 | 0 | | | |
| 7 | ន.ប ព្រះសីហនុ | **1** | **1** | **0** | 1 | 1 | 0 | | | | | | | | | | | | |
| 8 | ន.ប ស្ទឹងត្រែង | **2** | **3** | **0** | 2 | 3 | 0 | | | | | | | | | | | | |

| | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 9 | ន.ប ព្រះវិហារ | **3** | **3** | **1** | 1 | 1 | 1 | | | | | | | 2 | 2 | 0 | | | |
| 10 | ន.ប រតនគីរី | **1** | **2** | **0** | 1 | 2 | 0 | | | | | | | | | | | | |
| 11 | ន.ប បាត់ដំបង | **1** | **4** | **4** | 1 | 4 | 4 | | | | | | | | | | | | |
| 12 | ន.ប បន្ទាយមានជ័យ | **3** | **7** | **0** | 3 | 7 | 0 | | | | | | | | | | | | |
| 13 | ន.ប ក្រចេះ | **3** | **9** | **0** | 1 | 2 | 0 | | | | | | | 2 | 7 | 0 | | | |
| 14 | ន.ប មណ្ឌលគីរី | **1** | **2** | **0** | 1 | 1 | 0 | | | | | | | | | | 1 | 1 | 0 |
| 15 | ន.ប ប៉ៃលិន | **1** | **8** | **1** | 1 | 8 | 1 | | | | | | | | | | | | |
| 16 | ន.ប ឧត្តរមានជ័យ | **0** | **1** | **0** | | | | | | | | | | | | | 1 | 1 | 0 |
| | **សរុប** | **45** | **106** | **18** | **37** | 87 | 18 | | | | | | | **8** | 16 | 0 | **3** | 3 | 0 |

## *វត្ថុតាងគ្រឿងញៀន ចាប់យក ប្រចាំខែ ធ្នូ ឆ្នាំ២០១១ (រាយតាមអង្គភាពប្រតិបត្តិការ)*

| លរ | ឈ្មោះអង្គភាព | វត្ថុតាងចាប់យក | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | ***WY*** (គ្រាប់) | ***ICE*** (ក្រាម) | ***Heroine*** (ក្រាម) | ដើមកញ្ឆាម^២ | កញ្ឆាក្រៀម (ក្រាម) | ***Ecstasy*** (គ្រាប់) | ***Pseudo-Ephedrine*** | កូកាអ៊ីន (ក្រាម) | ប្រេងម្រះព្រៅភ្នំ |
| ***1*** | មន្ទីរប្រឆាំងគ្រឿងញៀន | *2.430* | *99,2* | | | | *1.250* | | | |
| ***2*** | ន.ប ភ្នំពេញ | | *33,32* | | | | | | | |
| ***3*** | ន.ប កណ្តាល | | *0,89* | | | | | | | |
| ***4*** | ន.ប កំពង់ស្ពឺ | | *0,20* | | | | | | | |
| ***5*** | ន.ប កំពង់ឆ្នាំង | | | | | | | | | *1.100* ***L*** |
| ***6*** | ន.ប កំពង់ចាម | | *9,92* | | | | | | | |
| ***7*** | ន.ប ព្រះសីហនុ | *12* | *0,09* | *1,2* | | | | | | |
| ***8*** | ន.ប ស្ទឹងត្រែង | *20* | *0,3* | | | | | | | |
| ***9*** | ន.ប ព្រះវិហារ | *15* | | | | *20* | | | | |
| ***10*** | ន.ប រតនគីរី | *7* | | | | | | | | |
| ***11*** | ន.ប បាត់ដំបង | *3* | | | | | | | | |
| ***12*** | ន.ប បន្ទាយមានជ័យ | *136* | | | | *100* | | | | |
| ***13*** | ន.ប ក្រចេះ | | *5* | | | | | | | |
| ***14*** | ន.ប មណ្ឌលគីរី | | | | | | | | | |
| ***15*** | ន.ប ប៉ៃលិន | *450* | | | | | | | | |
| ***16*** | ន.ប ឧត្តរមានជ័យ | | | | | | | | | |
| | សរុប | ***3.073*** | ***148,92*** | ***1,2*** | | ***120*** | ***1.250*** | | | ***1.100 L*** |

## ទ្រព្យសម្បត្តិ ពាក់ពន្ធ័បទល្មើសគ្រឿងញៀន

| ឈ្មោះ អ.ភ | រថយន្ត | ម៉ូតូ | ប្រាក់រៀល | ដុល្លារ USA | ប្រាក់ដុង | ប្រាក់បាត | | | |
|---|---|---|---|---|---|---|---|---|---|
| មន្ទីរ គ្រ.ញ | | ៤ | ១២០.០០០ | ៨០ | | ២០០ | | | |
| ន.ប ភ្នំពេញ | | ៨ | ៤៦៤.៥០០ | ៦៦ | | | | | |
| ន.ប កំ/ឆ្នាំង | ១ | | | | | | | | |
| ន.ប កំ/ចាម | | ២ | | | | | | | |
| ន.ប ព្រះសីហនុ | | | | ២០ | | | | | |
| ន.ប ប.ម.ជ័យ | | ១ | | ៣ | | | | | |
| **សរុប** | **១** | **១៥** | **៥៨៤.៥០០** | **១៦៩** | | **២០០** | | | |

## វត្ថុតាងផ្សេងៗ ពាក់ពន្ធ័បទល្មើសគ្រឿងញៀន

-មន្ទីរប្រឆាំង គ្រ.ញ — ម្សៅកេតាមីន ៣៧២ ក្រាម, អ៊ីរ៉ាមីន ១៥,៨៤ ក្រាម, ជញ្ជីង ១, លិខិតឆ្លងដែន ២ ក្បាល ។

-ន.ប ភ្នំពេញ — ជញ្ជីង ២, កាំបិត ១, ដាវ ១, ឧបករណ៍វេចខ្ចប់ និងប្រើប្រាស់គ្រឿងញៀនមួយចំនួន ។